ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
លេខាធិការដ្ឋានរដ្ឋបាល សរុប

# សមាសភាព

ចូលរួមកិច្ចប្រជុំពិភាក្សាបន្ត រៀបចំនីតិវិធី
សម្រាប់ការអនុវត្តសេចក្តីជូនដំណឹងលេខ ២៥៣ សជណ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧
របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពី "សំណើសុំគោលការណ៍ដោះស្រាយករណីទារក ដែលកើតដោយការជួលស្ត្រីខ្មែរ
ឲ្យពពោះជំនួស ដើម្បីយកទារកចេញទៅចិញ្ចឹមនៅក្រៅប្រទេស" ដឹកនាំកិច្ចប្រជុំដោយលោកជំទាវ **ជូ ប៊ុនអេង**
រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
ថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោង ០៩:០០នាទីព្រឹក
នៅសាលប្រជុំ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

១/ ឯកឧត្តម អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
២/ ឯកឧត្តម **យ៉ឹម វិរៈ** អគ្គលេខាធិការរង
៣/ លោកជំទាវ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង
៤/ ឯកឧត្តម **កើត រិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌
៥/ តំណាង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ០១រូប
៦/ តំណាង ក្រសួងសុខាភិបាល ០១រូប
៧/ តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ ០១រូប
៨/ តំណាងអគ្គនាយដ្ឋានអគ្គសញ្ញាណកម្ម ០១រូប
៩/ តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ០១រូប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កំណត់ហេតុ
## កិច្ចប្រជុំជំនាញពាក់ព័ន្ធ និងការរៀបចំបែបបទនីតិវិធី អនុវត្ត ស.ជ.ណ លេខ២៥៣ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែមេសា ថ្ងៃទីម្ភៃបួន វេលាម៉ោងប្រាំបួន និងសាមសិបនាទី នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានបើកកិច្ចប្រជុំជំនាញពាក់ព័ន្ធ និងការរៀបចំបែបបទនីតិវិធី អនុវត្ត សជណ លេខ ២៥៣ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួង អង្គភាពពាក់ព័ន្ធមួយចំនួនដូចជា៖

១. ឯ.ឧ.ឯក ថោង សំអាត អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
២. ឯ.ឧ.ឯក យឹម វិរៈ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
៣. ឯកឧត្តម អ៊ូច ចាន់ណូរ៉ា អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
៤. លោកជំទាវ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
៥. ឯ.ឧ.ឯក ហាស់ ម៉េងឡុង អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍
៦. ល.ឧ.ទោ គង់ ពុទ្ធី ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប គ.ជ.ប.ជ
៧. ល.ឧ.ទោ សំ វិរៈ អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍
៨. លោក អ៊ឹង វណ្ណថា ប្រធាននាយកដ្ឋាន កិច្ចការកុងស៊ុល នៃក្រសួងការបរទេស

ជាកិច្ចចាប់ផ្តើម **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍ស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានអញ្ជើញចូលរួមប្រជុំនាឱកាសនេះ។ លោកជំទាវ បានមានប្រសាសន៍ទាក់ទង សជណ លេខ២៥៣ ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១៧ ក្នុងការដោះស្រាយចំពោះមុខត្រូវផ្អែកលើគោលការណ៍ចម្បងដូចជា៖

១. ជានានូវការអនុវត្តន៍ តួនាទីរបស់អាជ្ញាធររដ្ឋក្នុងការការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ពលរដ្ឋខ្លួន ជាពិសេសលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីកុំឲ្យកម្ពុជាក្លាយជាគោលដៅ នៃការធ្វើអាជីវកម្មពពោះជំនួស និង

២. ជានាផលប្រយោជន៍របស់ទារកដែលកកំណើត ឬដែលបានកើតមកហើយ។ ដូចនេះយើងត្រូវដោះស្រាយបញ្ហាចំពោះមុខ អនុវត្តត្រឹមច្បាប់ដែលយើងមានបច្ចុប្បន្ន។

ការនាំយកទារកចេញត្រូវអនុលោមតាមច្បាប់រដ្ឋប្បវេណី របស់កម្ពុជាយើងគឺៈ

-ចំពោះស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ កូនដែលកើតមកត្រូវសន្មត់ថា ជាកូនរបស់ប្តីប្រពន្ធ នៃស្ត្រីពពោះ។ ឪពុកដែលជាម្ចាស់មេជីវិតចាំបាច់ត្រូវប្តឹងទៅតុលាការដើម្បីទាមទារ បិតុភាព(ភាពជាឪពុក) លើទារកនោះតាមផ្លូវច្បាប់ដោយបង្ហាញភស្តុតាងកោសល់វិច្ឆ័យ DNA (ឌីអិនអេ)។

-ចំពោះស្ត្រីនៅលីវ ឬពុំមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ឪពុកដែលជាម្ចាស់មេជីវិតត្រូវប្តឹងទៅតុលាការសុំសិទ្ធិគ្រប់គ្រងកូន ដើម្បីអាចនាំកូននោះចេញទៅក្រៅប្រទេសកម្ពុជាបាន។ ការសម្រេចអនុញ្ញាតនឹងអាចធ្វើបានដោយតុលាការ ប្រសិនបើស្ត្រីពពោះព្រមព្រៀងប្រគល់កូននោះឲ្យទៅឪពុកជាម្ចាស់មេជីវិតគ្រប់គ្រង។ កិច្ចសន្យាពពោះមិនអាចយកធ្វើជាមូលដ្ឋាន កំណត់ការព្រមព្រៀងនេះបានទេ ព្រោះជាកិច្ចសន្យាខុសច្បាប់។

-ដោយឡែក ចំពោះវិធានការព្រហ្មទណ្ឌ គឺនៅតែបន្តអនុវត្តចំពោះករណីជនល្មើសដែលជាអន្តរការី នៃការពពោះជំនួសស្របតាមមាត្រា ៣៣២ នៃក្រមព្រហ្មទណ្ឌ។

**លោកជំទាវ** បានលើកយកកិច្ចប្រជុំពិភាក្សាគ្នាកាលពីថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៦ ដោយយោងតាមរបាយការណ៍ពីក្រុមអ្នកស្រាវជ្រាវព័ត៌មានអូស្ត្រាលីឲ្យការសែត វិទ្យុសម្លេងអូស្ត្រាលីបានឲ្យដឹងថាៈ មានទារកមិនតិចជាង ៧០នាក់ទេ ដែលត្រូវបាននាំពីកម្ពុជាទៅប្រទេសអូស្ត្រាលីរួចហើយ។ តែតាមរបាយការណ៍ផ្ទាល់មាត់របស់ស្ថានទូតអូស្ត្រាលីថាៈ មានតែជាង១០នាក់ ប៉ុណ្ណោះ។ ផ្អែកតាមរបាយការរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្នុងឆ្នាំ ២០១៦ មានការនាំទារកចេញទៅក្រៅប្រទេសតាមច្រកទ្វារអន្តរជាតិចំនួន២៦នាក់ ក្នុងនោះចេញទៅប្រទេស ចិន ចំនួន១៤នាក់, ជប៉ុន ០៨នាក់, សហរដ្ឋអាមេរិក ចំនួន០៥នាក់, និងប្រទេសអូស្ត្រាលី ចំនួន០៦នាក់។ លោកជំទាវបានបញ្ជាក់បន្ថែមថាៈ បញ្ហាសំខាន់មួយទៀតគឺ ទារកដែលកើតឡើងពីការខ្ចី(ជួល) ពពោះជំនួសនឹងមិនអាចរក្សាទុកជាមួយអ្នកជួលពពោះបានឡើយ ព្រោះអ្នកទាំងនោះសុទ្ធតែជាគ្រួសារក្រីក្រ និងដឹងថាកូនទាំងនោះមិនមែនជាកូនរបស់គេឡើយ។ ដូចនេះគាត់ពុំមានលទ្ធភាពចិញ្ចឹមដល់ធំពេញវ័យឡើយ ហើយកូនទាំងនោះអាចជួបបញ្ហាប្រឈមគ្រោះថ្នាក់ ឬក្លាយជាបន្ទុករបស់រាជរដ្ឋាភិបាល។

ដើម្បីដោះស្រាយបញ្ហានេះ ចាំបាច់ត្រូវពិនិត្យករណីជាក់ស្តែង ពោលគឺត្រូវរៀបចំបែបបទនីតិវិធីសម្រាប់ការនាំចេញ ដែលមានការធានាទៅលើសុវត្ថិភាពទារក និងមិនមានហានិភ័យដោយអំពើជួញដូរមនុស្ស ឬត់ពន្ធទារកដើម្បីគោលដៅទុច្ចរិត។

មតិ **លោកជំទាវ រ៉ែន សិរីលក្ខិណា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ពាក់ព័ន្ធករណីនេះបើពិនិត្យលើ DNA (ឌីអិនអេ) របស់ម្ចាស់មេជីវិតពិតប្រាកដ វាពុំមានបញ្ហាអ្វីទេ ប៉ុន្តែអ្នកស្នើសុំខ្លះអាចយកមេជីវិតអ្នកដទៃ ហើយយកមកជួលស្ត្រីខ្មែរឲ្យពពោះជំនួស នោះគឺវាធ្វើឲ្យយើងជួបនូវបញ្ហាលំបាក។ ដូចនេះយើងគួរធ្វើតាមលក្ខណៈសុំកូនអន្តរជាតិ។ បញ្ហាមួយទៀតដែលយើងត្រូវយកចិត្តទុកដាក់ ដល់អ្នកស្នើសុំកូនដែលមានមេជីវិតពិតជាឪពុករបស់ទារកនោះ តើយើងត្រូវធ្វើយ៉ាងណាឲ្យពួកគាត់មានលក្ខណៈងាយស្រួលឆាប់រហ័សក្នុងការនាំយកទារកចេញទៅក្រៅប្រទេស?

មតិ **លោក អ៊ុំ វណ្ណថា** ប្រធាននាយកដ្ឋាន កិច្ចការកុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំពោះករណីនេះគួរឲ្យស្ថានទូតសាមីធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់ មកក្រសួងការបរទេស ដើម្បីធ្វើការជូនដំណឹងបន្តទៅក្រសួងមហាផ្ទៃក្នុងការអនុវត្តន៍ លើការស្នើសុំរបស់ស្ថានទូតសាមី និងអ្នកស្នើសុំកូន(ទារក)។

មតិ **ឯកឧត្តម អ៊ុច ចាន់ណូរ៉ា** អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ការអនុវត្ត សជណ លេខ២៥៣ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ តួនាទី និងភារកិច្ចសំខាន់ចំពោះមុខគឺ ក្រសួងយុត្តិធម៌ ត្រូវដើរតួព្រោះអ្វីៗដែលយើងទទួលធ្វើត្រូវតែឆ្លងកាត់តុលាការជាការចាំបាច់ អមដោយការរឹតបន្តឹងវិធានការរដ្ឋបាល ពិសេសការត្រួតពិនិត្យតាមគ្លីនិកមួយចំនួន ដែលមានបច្ចេកវិទ្យាពាក់ព័ន្ធនឹងការពពោះនោះ។ ចំពោះករណីនេះទារកកើតចេញមកត្រូវចុះសំបុត្រកំណើតនៅក្នុងភូមិ/ឃុំរបស់ខ្លួនសិន រួចហើយយើងមានសាលក្រមតុលាការចុះសំបុត្រកំណើតថ្មី ធ្វើផ្ទាល់នៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មតែម្តង។ ចំពោះករណីនេះសាមីខ្លួនត្រូវធ្វើការស្នើសុំចូលទៅស្ថានទូតរបស់ខ្លួន ដើម្បីឲ្យស្ថានទូតនោះធ្វើការស្នើសុំមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិតាមការស្នើសុំរបស់អ្នកស្នើសុំ។

ប្រសាសន៍ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ថោង សំរេត** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចំពោះភារកិច្ចរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ តើយើងត្រូវអនុវត្តពីក្រសួងស្ថាប័នណាមុន ពេលទទួលបានការស្នើសុំរបស់អ្នកស្នើសុំ? ហើយការកំណត់រយៈពេល ៩ខែ ១០ថ្ងៃ ត្រូវចាប់ពីពេលណាទៅ? សម្រាប់អ្នកស្នើសុំគឺត្រូវធ្វើតាមបែបបទនីតិវិធី នៃការនាំទារកចេញ ដូចជា៖

- លិខិតស្នើសុំរបស់អ្នកសុំកូន(ឪពុក)
- លិខិតព្រមព្រៀងប្រគល់របស់ស្ត្រីពពោះ(ម្តាយ)
- នីតិវិធី និងស្ថាប័នអនុវត្ត

ព្រោះបែបបទ និងនីតិវិធីនេះត្រូវធ្វើការស្នើសុំរៀបចំជា សេចក្តីជូនដំណឹង ឬអនុក្រឹត្យដើម្បីអាចអនុវត្តបណ្តោះអាសន្ន ក្នុងដំណាក់កាលដែលមិនទាន់មានច្បាប់ស្តីពី ការខ្ចី ឬជួលពពោះជំនួសនៅឡើយ។

មតិ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ហាស់ម៉េងឡុង** អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានឯកភាពលើមតិយោបល់ដែលបានលើកឡើង ចំពោះអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នឹងធ្វើតាមការស្នើសុំរបស់សាមីខ្លួនអ្នកសុំ ប្រសិនបើមានគោលការណ៍ ឬលិខិតឯកភាពណាមួយពីក្រសួងមហាផ្ទៃ។

មតិ **ឯកឧត្តម ឧត្តមសេនីយ៍ឯក យឹម វិរៈ** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឯកភាពមតិដែលបានលើកឡើងរបស់អង្គប្រជុំ ដំណោះស្រាយចំពោះមុខមកទល់ពេលនេះ គឺពុំមានអ្វីគួរឲ្យស្មុគស្មាញទៀតទេព្រោះអីក្រសួងយុត្តិធម៌ និងតុលាការជាអ្នកសម្រេចលើករណីនេះ។ ដូចនេះក្រសួងយុត្តិធម៌គេអាចបញ្ជា ឬជូនដំណឹងដល់សាលាដំបូងរាជធានី/ខេត្ត ទាំង២៥ បានជ្រាបហើយ។ បញ្ហាសំខាន់គឺ ក្រសួងស្ថាប័ន អង្គភាពពាក់ព័ន្ធត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមជំនាញរបស់ខ្លួន។

ចុងបញ្ចប់ នៃកិច្ចប្រជុំ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានស្នើសុំឲ្យក្រសួងស្ថាប័ន អង្គភាពពាក់ព័ន្ធទាំងអស់ត្រូវរៀបចំនីតិវិធីរបស់ខ្លួនលើករណីនេះ

ហើយប្រហែលនៅសប្តាហ៍ក្រោយយើងត្រូវធ្វើការជួបប្រជុំគ្នាទៀតដើម្បីកំណត់ពីតួនាទី ភារកិច្ចរបស់ក្រសួងស្ថាប័ន អង្គភាពណា ត្រូវធ្វើអ្វីលើបញ្ហានេះ?

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ដប់មួយ និងសាមសិបនាទី ថ្ងៃខែឆ្នាំដដែល។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មេសា ឆ្នាំ២០១៧

**អ្នកធ្វើកំណត់ហេតុ**

វរសេនីយ៍ទោ ឡិក-សឿង

**គោរពជូន**

**លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៧

ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប

ឧត្តមសេនីយ៍ទោ. គង់-ពុទ្ធី

បានឃើញ

05/05/17

ជូ-ប៊ុនអេង